**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ២៥០
ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៣
**<u>សាលដីកា</u>**
លេខ: ២០៦
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា .................

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម ............... ជាព្រះរាជអាជ្ញារង
-លោក **សោម សិរិវិឌ្ឍ** ជាចៅក្រមរបាយការណ៍

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១០ (ឈ) ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥២៨ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ ឡសរ (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅផ្ទះលេខ៥៣៥ ផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកង២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះឡាយ ប៉ោយ (រ) ម្តាយឈ្មោះឡាំង ស្រ៊ុន ម៉េម៉ាយ កូន០៦នាក់ ។

មានមេធាវីលោក ................. ។

ចុងចម្លើយឈ្មោះ វ៉ែល វីរៈសង្គ្រាម (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៦ឆ្នាំជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ ១៦០ ផ្លូវទំនប់ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវរាជធានីភ្នំពេញ ។ ឪពុកឈ្មោះវ៉ែល ឌឹម(ស) ម្តាយឈ្មោះងិន យន(ស) ប្រពន្ធឈ្មោះង៉ែត ច័នសុមុនី ។

មានមេធាវីលោក ................. ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារប្រាក់ថ្លៃទិញផ្ទះ និង ដីចំនួន៤៣.០០០$US ទាមទារប្រាក់សគុណ ១៥០០ដុល្លាអាមេរិក និងជំងឺចិត្ត ១០.០០០$US

បានឃើញបណ្តឹងសាទុក្ខលេខ ១៥៧ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះ វ៉ែល វីរៈសង្គ្រាម ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០(ឈ) ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៥០ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី១៥-៦-២០០១ ថា : ខ្លួនប្តឹងសុំឱ្យឈ្មោះវ៉ែល វីរៈសង្គ្រាម និងឈ្មោះង៉ែត ច័ន្ទសុមុនី អនុវត្តកិច្ចសន្យាលក់ដី និងផ្ទះចុះថ្ងៃទី០៦-០២-២០០១ មូលហេតុអ្នកទាំងពីរបានលក់ដី និង ផ្ទះឱ្យខ្លួនរួចហើយ មិនគោរពតាមកិច្ចសន្យា ។

តាមពាក្យបណ្តឹងមេធាវី................ តំណាងឱ្យដើមចោទចុះថ្ងៃទី១៦-៧-២០០១ថា ខ្លួនប្តូរកម្មវត្ថុបណ្តឹងដោយប្តឹងទាមទារប្រាក់ថ្លៃទិញផ្ទះនិងដីចំនួន៤៣០០០$US និង ទារប្រាក់សគុណ ១៥០០$US ក្នុងមួយខែ និងជំងឺចិត្តចំនួន១០.០០០$US ពីឈ្មោះវ៉ែល វីរៈសង្គ្រាម និងង៉ែត ច័ន្ទសុមុនី ។ មូលហេតុបានទទួលប្រាក់ពីកូនក្តីខ្លួនគ្រប់ចំនួនរួចហើយ និងមិនគោរពកិច្ចសន្យាលក់ ទិញដី និងផ្ទះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៤(ខ) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៦-៧-២០០១ របស់មេធាវីតំណាងដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ពាក្យសុំការពារក្តីនិងជាតំណាងឱ្យដើមចោទឈ្មោះឡាយសារឹមចុះថ្ងៃទី២៥ខែមិថុនាឆ្នាំ២០០១ របស់មេធាវី................ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-បង្គាប់ឱ្យឈ្មោះវ៉ែល វីរៈសង្គ្រាម និងប្រពន្ធឈ្មោះង៉ែត ច័ន្ទសុមុនី ប្រគល់ប្រាក់ថ្លៃទិញផ្ទះនិងដីចំនួន៤៣.០០០$US(បួនម៉ឺនបីពាន់ដុល្លាអាមេរិក)និងឱ្យសងជំងឺចិត្តចំនួន១៥០០០$US (មួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) ទៅឱ្យឈ្មោះឡសរ ជាដើមចោទ ចំពោះការ ទាមទារការប្រាក់ និងប្រាក់សគុណ ត្រូវបដិសេធចោល ។

៤-បើមិនសង ឬគ្មានលទ្ធភាពសង ត្រូវរឹបអូសផ្ទះ និងដីលេខ១៦០J ផ្លូវទំនប់ភូមិទួលគោក សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខចVI080 ចុះថ្ងៃទី០៥-១១-១៩៩៦ ដើម្បីលក់ឡាយឡុងជានាសំណង បើវឹងទទឹងត្រូវចាប់ដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី០២-៥-១៩៩២ ។

៥-បង្គាប់ឱ្យឈ្មោះវ៉ែល វីរៈសង្គ្រាម និងប្រពន្ធឈ្មោះង៉ែត ច័ន្ទសុមុនី បង់ប្រាក់ ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់ អ្នកប្រគល់ដីកាកោះ ២.០០០រៀល រង្វាន់សាក្សី ៣.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចមកហើយ ។

កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះវ៉ែល វីរៈសង្គ្រាម សងប្រាក់ ៧.០០០រៀល ទៅឱ្យដើមចោទវិញ និងឲ្យ បង់ពន្ធសមាមាត្រ១% លើចំនួនប្រាក់ដែលត្រូវសងទាំងអស់ ប្រាក់នេះ ត្រូវបង់ចូលថវិការដ្ឋ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៦-សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាង ដើមចោទកំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៤១(ខ) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះវ័ល វីរៈសង្គ្រាម ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៩៤(ខ) ចុះថ្ងៃទី០៤ខែតុលាឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣៥(ខ) ចុះថ្ងៃទី១០ខែមេសា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១៦-១០-២០០១របស់ដើមបណ្តឹងទាស់ឈ្មោះ វ័ល វីរៈសង្គ្រាម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៩៤(ខ) ចុះថ្ងៃទី០៤-១០-២០០១ ទុកជាបានការទាំងមូល ។

៣-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីតំណាងចុងបណ្តឹងទាស់ កំបាំងមុខដើមបណ្តឹងទាស់ ចាត់ទុកដូចជាចំពោះមុខ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុង កំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៨(ខ) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះវ័ល វីរៈសង្គ្រាម ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៣៥ (ខ) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៩៤(ឈ)ចុះថ្ងៃទី១៧ ខែតុលាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះវ័ល វីរៈសង្គ្រាម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣៥(ខ) ចុះថ្ងៃទី១០-០៤-២០០២ របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ចំនួន១៣.០០០៛ ដែលដើម ចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៩៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០៛ និង លើអាជ្ញាធរតុលាការចំនួន៥.០០០៛ ។ នៅពេលសាលដីកានេះចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយសងប្រាក់១៣.០០០៛ នេះទៅដើមចោទវិញ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៥-១០-២០០២ ចំពោះមុខ មេធាវីតំណាងឱ្យដើមចោទ និងកំបាំងមុខចុងចម្លើយ ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១៧២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ឈ្មោះវ័ល វីរៈសង្គ្រាម ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៩៤(ឈ)ចុះថ្ងៃទី១៧ខែតុលាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០(ឈ)ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១៣-១១-២០០២ របស់ឈ្មោះវ៉ល វីរៈសង្គ្រាម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៩៤(ឈ)ចុះថ្ងៃទី១៧-១០-២០០២របស់ សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី០២-០១-២០០៣ ចំពោះមុខមេធាវីតំណាងឱ្យដើមចោទក៏បាំងមុខចុងចម្លើយនិងប្រកាសជាសាធារណៈនៅថ្ងៃទី០៩-០១-២០០៣ ចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ តែចាត់ទុកចំពោះមុខ ។ បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៥៧ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះវ៉ល វីរៈសង្គ្រាម ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០(ឈ) ចុះថ្ងៃទី០៩ ខែមករាឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១០(ឈ)ចុះថ្ងៃទី០៩-០១-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈ ត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ................ ជាមេធាវីការពារឱ្យអ្នកស្រី ឡសរ បានលើកឡើងថា : ក្រោយពីបានពិនិត្យគ្រប់ឯកសារនៅក្នុងសំណុំរឿង និងក្រោយពីបាន ស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ឃើញថាកូនក្តីខ្លួនបានទិញផ្ទះពីលោកវ៉ល វីរៈសង្គ្រាម ក្នុងតំលៃ ៤៣.០០០ដុល្លាអាមេរិក ពិតប្រាកដមែន ហើយការទិញនេះ គឺតាមរយៈលោកឈី ធរិន ជាអ្នកទំនាក់ទំនងនាំទៅទិញ ។ ក្នុងការទិញនេះ លោកចាន់ វាសនា ជាកូនរបស់អ្នកស្រីឡាយសារឹម ដែលជាកូនក្តីរបស់ខ្លួន បានទៅទិញជាមួយលោកឈី ធរិន ដែលជាអ្នកដឹកនាំនោះ ត្រូវរ៉ូវតម្លៃគ្នា ក៏បានទៅប្រគល់លុយនៅផ្ទះលោក ស៊ិន ប៊ុនថន ដែលជាម្ចាស់បំណុលរបស់លោកវ៉ល វីរៈសង្គ្រាម ព្រោះប្លង់ផ្ទះនេះលោកវីរៈសង្គ្រាម បានដាក់បញ្ចាំទៅនឹងលោកស៊ិន ប៊ុនថន ។ក្នុងការទិញនោះ ពុំបានកាត់ឈ្មោះទេ ព្រោះភាគីអ្នកលក់បានសុំសិទ្ធិទិញវិញក្នុងតំលៃដើមរយៈពេល ៧ខែក្រោយ ដោយសន្យាឱ្យសគុណចំនួន ១៥០០ដុល្លា ក្នុងមួយខែ មកភាគីអ្នកទិញ កូនក្តីខ្លួនក៏ យល់ព្រម សុខចិត្តធ្វើតាមដោយឱ្យលោក ឈី ធរិន ជាអ្នករៀបចំឯកសារ ។ ការប្រគល់ប្រាក់ជាក់ស្តែងនៅថ្ងៃទី០៩-១២-២០០១ ទីកន្លែងផ្ទះលោកស៊ិន ប៊ុនថន ។ ក្នុងប្រាក់ ៤៣.០០០ដុល្លានេះ លោកសង្គ្រាម ទទួលបាន ៣៩.៣៤៥ដុល្លា ព្រោះត្រូវដកប្រាក់កុំមីស្យុង ២១៥០ដុល្លា ថ្លៃធ្វើលិខិតស្លាម ៥ដុល្លា និងប្រាក់ជូនសគុណ ១៥០០ដុល្លា ។ រឿងក្តីនេះ តុលាការថ្នាក់ក្រោមបានធ្វើ ការអង្កេតគ្រប់គ្រាន់ហើយ ខ្លួនសុំសំណូមពរឯកឧត្តម

ប្រធាននិងក្រុមប្រឹក្សាជំនុំជំរះតុលាការកំពូលមេត្តាសម្រេចតម្កល់សាលដីកាលេខ១០(ឈ)ចុះថ្ងៃទី០៩-០១-២០០៣ ទុកជាបានការទាំងមូល ។

ក្រោយពីបានស្តាប់របាយការណ៏របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៥៧ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣របស់ឈ្មោះ វ៉ល វីរៈសង្គ្រាម ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយកមកជំនុំជំរះ បានតាមបញ្ញត្តិ មាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោកវ៉ល វីរៈសង្គ្រាមអះអាងថាៈ លោកពុំបានទទួលប្រាក់ ចំនួន៤៣.០០០ដុល្លាអាមេរិកពីដើមចោទនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតាមលិខិតទទួលប្រាក់ចុះ ថ្ងៃទី០៧-០២-២០០១ លោកវ៉ល វីរៈសង្គ្រាម និងអ្នកស្រីង៉ែត ច័ន្ទសុមុនី បានផ្តិតមេដៃបញ្ជាក់ថា លោក និងអ្នកស្រីពិតជាបានទទួលប្រាក់ ៤៣.០០០ដុល្លាអាមេរិករួចហើយ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថា ដើមចោទបានបន្លំ និងក្លែងលិខិតកេងយកប្រាក់នេះទៅវិញទេ ។ ដូច្នេះចុងចម្លើយ មានកាតព្វកិច្ចត្រូវសងប្រាក់នេះ ទៅដើមចោទវិញតាមមាត្រា ២២, ២៩ និង ៥៦ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨-១០-១៩៨៨ ។

- យល់ឃើញថា ចុងចម្លើយបានធ្វើសំណូមពរតាមលិខិតចុះថ្ងៃទី០៣-១០-២០០៣សុំឱ្យតុលាការកំពូលពន្យាពេលចាត់ការរឿងក្តីនេះសិន តុលាការកំពូលបានពន្យាពេលតាំងពីពេលនោះ រហូតដល់ពេលនេះអស់ពេលជិត១ឆ្នាំហើយ ហើយនៅពេលសវនាការនេះ លោកក៏សុំពន្យាពេល ទៀត ។ ប៉ុន្តែបើតុលាការកំពូលពន្យាពេលនេះតទៅទៀត ក៏ដើមចោទពុំសុខចិត្តដែរ ពីព្រោះដើម ចោទបានដាក់ពាក្យសុំឱ្យតុលាការកំពូលជំនុំជំរះរឿងនេះឱ្យបានឆាប់ដែរ ។ ដូច្នេះ តុលាការកំពូល សម្រេចជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ដើមចោទពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០(ឈ) ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ។

## ហេតុច្នេះ

## វិនិច្ឆ័យសេចក្តីកំបាំងមុខក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ១៥៧ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះវ៉ល វីរៈសង្គ្រាម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០(ឈ) ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីដែលដើមចោទ បានបង់នៅតុលាការកំពូលចំនួន១៩.០០០៛ គឺ :

-ពន្ធចុះបញ្ជីក្ដី នឹងពន្ធហ្នឹងចំនួន៤.០០០៛ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន៨០០៛សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

+ តម្រូវឱ្យលោក វ៉ែ វិរៈសង្គ្រាម សងប្រាក់ចំនួន១៩.០០០៛នេះ ទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួន ១% លើចំនួនទឹកប្រាក់ដែលត្រូវសងដើមចោទ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤ ។